ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ:..០២៩..... ស.ហ.វ.........

SOCIAL PROTECTION IN CAMBODIA

# សេចក្តីសម្រេច
# ស្តីពី
# ការនិរាករណ៍សេចក្តីសម្រេចលេខ ០១៨ សហវ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ ស្តីពីយន្តការ និងនីតិវិធីនៃការអនុវត្តវិធានការគោលនយោបាយអន្តរាគមន៍ជំនួយសង្គម របស់រាជរដ្ឋាភិបាល ដើម្បីគាំពារប្រជាពលរដ្ឋដែលរងគ្រោះ ឬរងផលប៉ះពាល់ធ្ងន់ធ្ងរ ពីជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/២៤១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការរដ្ឋបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia
ទូរសព្ទលេខ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone:(+855)23 890 666

- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៤៩ សសរ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ ២០២១ ស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- បានឃើញសេចក្តីសម្រេចលេខ ០១៨ សហវ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ ស្តីពីយន្តការ និងនីតិវិធីនៃការអនុវត្តវិធានការគោលនយោបាយអន្តរាគមន៍ជំនួយសង្គមរបស់រាជរដ្ឋាភិបាល ដើម្បីគាំពារប្រជាពលរដ្ឋដែលរងគ្រោះ ឬរងផលប៉ះពាល់ធ្ងន់ធ្ងរ ពីជំងឺកូវីដ-១៩ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១
- បានឃើញសេចក្តីណែនាំលេខ០១ សណន ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ស្តីពីវិធានការលម្អិតដើម្បីរឹតបន្តឹងការអនុវត្តសេចក្តីសម្រេចស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- យោងតាមតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាជាតិគាំពារសង្គម

## សម្រេច

**ប្រការ១.-**

ត្រូវទុកជានិរាករណ៍សេចក្តីសម្រេចលេខ ០១៨ សហវ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ ស្តីពីយន្តការ និងនីតិវិធីនៃការអនុវត្តវិធានការគោលនយោបាយអន្តរាគមន៍ជំនួយសង្គមរបស់រាជរដ្ឋាភិបាល ដើម្បីគាំពារប្រជាពលរដ្ឋដែលរងគ្រោះ ឬរងផលប៉ះពាល់ធ្ងន់ធ្ងរ ពីជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ ដោយអនុវត្តនូវជំនួយសង្គ្រោះបន្ទាន់ ដូចមានចែងក្នុងសេចក្តីណែនាំលេខ០១ សណន ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ស្តីពីវិធានការលម្អិតដើម្បីរឹតបន្តឹងការអនុវត្តសេចក្តីសម្រេចស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ជំនួសវិញ។

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

អនុប្រធាន និងសមាជិកក្រុមប្រឹក្សាជាតិគាំពារសង្គម, រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី, ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការប្រតិបត្តិ នៃក្រុមប្រឹក្សាជាតិគាំពារសង្គម, នាយកខុទ្ទកាល័យ, អគ្គលេខាធិការ, ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក, អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន, អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៨ កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខៈ..០១៤... ស.ហ.វ.........

SOCIAL PROTECTION IN CAMBODIA

# សេចក្តីសម្រេច
# ស្តីពី
# យន្តការ និងនីតិវិធីនៃ
# ការអនុវត្តវិធានការគោលនយោបាយអន្តរាគមន៍ជំនួយសង្គមរបស់រាជរដ្ឋាភិបាល ដើម្បីគាំពារប្រជាពលរដ្ឋដែលរងគ្រោះ ឬរងផលប៉ះពាល់ធ្ងន់ធ្ងរ ពីជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/២៤១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

- បានឃើញអនុក្រឹត្យលេខ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការរដ្ឋបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៤៩ សសរ ចុះថ្ងៃទី ១៤ ខែមេសា ឆ្នាំ ២០២១ ស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- យោងតាមតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាជាតិគាំពារសង្គម

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

សេចក្តីសម្រេចនេះ មានគោលបំណងកំណត់យន្តការ និងនីតិវិធីដាក់ឱ្យអនុវត្តវិធានការអន្តរាគមន៍ជំនួយសង្គមរបស់រាជរដ្ឋាភិបាល ដើម្បីគាំពារប្រជាពលរដ្ឋដែលរងគ្រោះ ឬរងផលប៉ះពាល់ធ្ងន់ធ្ងរពីជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១។

**ប្រការ២.-**

សេចក្តីសម្រេចនេះ មានវិសាលភាពអនុវត្តចំពោះប្រជាពលរដ្ឋខ្មែរ ដែលរងគ្រោះ និងរងផលប៉ះពាល់ធ្ងន់ធ្ងរពីជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ ដូចខាងក្រោម÷

- គ្រួសារមានជីវភាពលំបាក រស់នៅក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ដែលត្រូវបានអនុវត្តវិធានការបិទខ្ទប់
- គ្រួសារដែលមានសមាជិកទទួលរងជំងឺកូវីដ-១៩ តែមិនមានអ្នកស្លាប់ នៅទូទាំងប្រទេស, និង
- គ្រួសារដែលមានសមាជិកស្លាប់ដោយសារជំងឺកូវីដ-១៩ នៅទូទាំងប្រទេស។

## ជំពូកទី២

## ការខ្ទបត្តម្ភ និងលក្ខខណ្ឌនៃការទទួលផល

**ប្រការ៣.-**

- **គ្រួសារមានជីវភាពលំបាក រស់នៅក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ដែលត្រូវបានអនុវត្តវិធានការបិទខ្ទប់** សំដៅដល់គ្រួសារដែលមានបណ្ណសមធម៌, គ្រួសារដែលជាកម្មករនិយោជិត និងដែលប្រកបមុខរបរមានហានិភ័យការងារខ្ពស់ រួមទាំងកម្មករនិយោជិតក្រៅប្រព័ន្ធ អាជីវករលក់ដូរតូចតាច និងគ្រួសារដទៃទៀតដែលកំណត់ដោយអាជ្ញាធរមូលដ្ឋាន និងដែលរស់នៅក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ដែលត្រូវបានអនុវត្តវិធានការបិទខ្ទប់
- **គ្រួសារដែលមានសមាជិកទទួលរងជំងឺកូវីដ-១៩ តែមិនមានអ្នកស្លាប់ នៅទូទាំងប្រទេស** សំដៅដល់គ្រួសារដែលមានសមាជិកឆ្លងជំងឺកូវីដ-១៩ ស្ថិតក្នុងបញ្ជីផ្លូវការចេញដោយរដ្ឋបាលរាជធានី ខេត្ត និងមិនមានសមាជិកស្លាប់ដោយសារជំងឺកូវីដ-១៩
- **គ្រួសារដែលមានសមាជិកស្លាប់ដោយសារជំងឺកូវីដ-១៩ នៅទូទាំងប្រទេស** សំដៅដល់គ្រួសារដែលមានសមាជិកស្លាប់ដោយសារជំងឺកូវីដ-១៩ ស្ថិតក្នុងបញ្ជីផ្លូវការចេញដោយរដ្ឋបាលរាជធានី ខេត្ត និងមានលិខិតមរណភាពផ្លូវការចេញដោយមូលដ្ឋានសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ច។

**ប្រការ៤.-**

គ្រួសារមានជីវភាពលំបាក រស់នៅក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ដែលត្រូវបានអនុវត្តវិធានការបិទខ្ទប់, គ្រួសារដែលមានសមាជិកទទួលរងជំងឺកូវីដ-១៩ តែមិនមានអ្នកស្លាប់ នៅទូទាំងប្រទេស និងគ្រួសារដែលមានសមាជិកស្លាប់ដោយសារជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ត្រូវទទួលបានការឧបត្ថម្ភជាសាច់ប្រាក់ចំនួន ០១ (មួយ) លើកគត់ តាមកម្រិត ដូចខាងក្រោម÷

| ចំនួនសមាជិកគ្រួសារ (នាក់) | កម្រិតប្រាក់ឧបត្ថម្ភ | | |
|---|---|---|---|
| | រាជធានីភ្នំពេញ និងក្រុងតាខ្មៅ | ទីប្រជុំជនតាមខេត្ត | ជនបទទូទាំងប្រទេស |
| ១ | ១៦០ ០០០ រៀល | ១៦០ ០០០ រៀល | ១៦០ ០០០ រៀល |
| ២ - ៣ | ២០០ ០០០ រៀល | ២០០ ០០០ រៀល | ២០០ ០០០ រៀល |
| ចាប់ពី ៤ ឡើងទៅ | ២៤០ ០០០ រៀល | ២៤០ ០០០ រៀល | ២៤០ ០០០ រៀល |

ការឧបត្ថម្ភជាសាច់ប្រាក់នេះ មិនអនុវត្តចំពោះគ្រួសារមានបណ្ណសមធម៌ ដែលបាន និងកំពុងទទួលបានការឧបត្ថម្ភក្រោម“កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩” ទេ។

**ប្រការ៥.-**

គ្រួសារមានជីវភាពលំបាក រស់នៅក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ដែលត្រូវបានអនុវត្តវិធានការបិទខ្ទប់, គ្រួសារដែលមានសមាជិកទទួលរងជំងឺកូវីដ-១៩ តែមិនមានអ្នកស្លាប់ នៅទូទាំងប្រទេស និងគ្រួសារដែលមានសមាជិកស្លាប់ដោយសារជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ត្រូវទទួលបានការឧបត្ថម្ភស្បៀងអាហារ ចំនួន ០១ (មួយ) លើកគត់ ដូចខាងក្រោម÷

- អង្ករ ចំនួន ២៥ (ម្ភៃប្រាំ) គីឡូក្រាម
- មី ចំនួន ១ (មួយ) កេសតូច
- ទឹកត្រី ចំនួន ១ (មួយ) យួរ ស្មើនឹង ៦ (ប្រាំមួយ) ដប, និង
- ទឹកស៊ីអ៊ីវ ចំនួន ១ (មួយ) យួរ ស្មើនឹង ៦ (ប្រាំមួយ) ដប។

**ប្រការ៦.-**

គ្រួសារមានជីវភាពលំបាក រស់នៅក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ដែលត្រូវបានអនុវត្តវិធានការបិទខ្ទប់ ត្រូវទទួលបានការឧបត្ថម្ភកម្រិតអប្បបរមាលើថ្លៃប្រើប្រាស់ទឹកស្អាត និងអគ្គិសនី ចំនួន ២ (ពីរ) ខែ។

គ្រួសារដែលមានសមាជិកទទួលរងជំងឺកូវីដ-១៩ តែមិនមានអ្នកស្លាប់ នៅទូទាំងប្រទេស ទទួលបានការឧបត្ថម្ភកម្រិតអប្បបរមាលើថ្លៃប្រើប្រាស់ទឹកស្អាត និងអគ្គិសនី ចំនួន ៣ (បី) ខែ។

គ្រួសារដែលមានសមាជិកស្លាប់ដោយសារជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ទទួលបានការឧបត្ថម្ភកម្រិតអប្បបរមាលើថ្លៃប្រើប្រាស់ទឹកស្អាត និងអគ្គិសនី ចំនួន ៥ (ប្រាំ) ខែ។

កម្រិតនៃការឧបត្ថម្ភថ្លៃប្រើប្រាស់ទឹកស្អាត និងអគ្គិសនី មានដូចខាងក្រោម÷

| **ចំនួនសមាជិកគ្រួសារ** | **ថ្លៃទឹកស្អាត** | **ថ្លៃអគ្គិសនី** |
|---|---|---|
| ១ នាក់ | ៨ ៧៥០ រៀល | ១៩ ២០០ រៀល |
| ២ - ៣ នាក់ | ២២ ៥០០ រៀល | ៤២ ៧០០ រៀល |
| ចាប់ពី ៤ នាក់ ឡើងទៅ | ៣១ ២៥០ រៀល | ៦១ ០០០ រៀល |

## ជំពូកទី៣

## តួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័នដឹកនាំ និងអនុវត្តកម្មវិធី

**ប្រការ៧.-**

រដ្ឋបាលរាជធានី ខេត្ត ទទួលបន្ទុកអនុវត្តវិធានការអន្តរាគមន៍ជំនួយសង្គមរបស់រាជរដ្ឋាភិបាល ដើម្បីគាំពារប្រជាពលរដ្ឋដែលរងគ្រោះ ឬរងផលប៉ះពាល់ធ្ងន់ធ្ងរ ពីជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ ដោយមានការសម្របសម្រួលពីអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។ ក្នុងការអនុវត្តវិធានការអន្តរាគមន៍ជំនួយសង្គមនេះ រដ្ឋបាលរាជធានី ខេត្ត ត្រូវសហការជាមួយក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន និងអ្នកស្ម័គ្រចិត្តនៃសហភាពសហព័ន្ធយុវជនកម្ពុជា។

## ជំពូកទី៤

## កញ្ចប់ថវិកា និងនីតិវិធីអនុវត្តកម្មវិធី

**ប្រការ៨.-**

កញ្ចប់ថវិកាសម្រាប់អនុវត្តវិធានការអន្តរាគមន៍ជំនួយសង្គមរបស់រាជរដ្ឋាភិបាល ដើម្បីគាំពារប្រជាពលរដ្ឋដែលរងគ្រោះ ឬរងផលប៉ះពាល់ធ្ងន់ធ្ងរ ពីជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ ត្រូវគ្រោង និងកត់ត្រានៅក្នុងក្របខណ្ឌនៃកញ្ចប់ថវិការបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជំពូក ៦២០២៨ (ជំនួយសង្គម)។

**ប្រការ៩.-**

ថវិកាសម្រាប់អនុវត្តវិធានការអន្តរាគមន៍ជំនួយសង្គមរបស់រាជរដ្ឋាភិបាល ដើម្បីគាំពារប្រជាពលរដ្ឋដែលរងគ្រោះ ឬរងផលប៉ះពាល់ធ្ងន់ធ្ងរ ពីជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ ត្រូវបានបើកផ្តល់ជាបុរេប្រទានដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអនុវត្តទូទាត់ជម្រះចំណាយតាមក្រោយ។

**ប្រការ១០.-**

រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំសំណើសុំបុរេប្រទានថវិកា និងកញ្ចប់ឧបត្ថម្ភស្បៀងអាហារ ដោយមានបញ្ជាក់ពីបុគ្គល ឬគណនីធនាគារត្រូវទទួលប្រាក់ ដែលត្រូវភ្ជាប់ជាមួយនូវតារាងគម្រោងចំណាយថវិកា, កញ្ចប់ឧបត្ថម្ភស្បៀងអាហារ និងឯកសារពាក់ព័ន្ធ តាមគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី១ នៃសេចក្តីសម្រេចនេះ ដើម្បីដាក់ជូនរដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម តាមរយៈអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីពិនិត្យ សម្រេច។ ឯកសារពាក់ព័ន្ធ ដែលរដ្ឋបាលរាជធានី ខេត្ត ត្រូវភ្ជាប់ជាមួយ មានដូចខាងក្រោម÷

១. បញ្ជីគ្រួសារមានជីវភាពលំបាកដែលរស់នៅក្នុងតំបន់ដែលត្រូវបានអនុវត្តវិធានការបិទខ្ទប់
- តារាងគម្រោងចំណាយថវិកា និងកញ្ចប់ឧបត្ថម្ភស្បៀងអាហារយោងតាមបញ្ជីគ្រួសារ
- ដីកា ឬសេចក្តីសម្រេចអនុវត្តវិធានការបិទខ្ទប់តាមតំបន់ភូមិសាស្ត្រ

២. បញ្ជីគ្រួសារដែលមានសមាជិកទទួលរងជំងឺកូវីដ-១៩ តែមិនមានអ្នកស្លាប់
- តារាងគម្រោងចំណាយថវិកា និងកញ្ចប់ឧបត្ថម្ភស្បៀងអាហារយោងតាមបញ្ជីគ្រួសារ
- លិខិតបញ្ជាក់អ្នកជំងឺកូវីដ-១៩ ដែលចេញដោយមន្ទីរពេទ្យ ឬមន្ទីរពិសោធន៍
- សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ

៣. បញ្ជីគ្រួសារដែលមានសមាជិកស្លាប់ដោយសារជំងឺកូវីដ-១៩
- តារាងគម្រោងចំណាយថវិកា និងកញ្ចប់ឧបត្ថម្ភស្បៀងអាហារយោងតាមបញ្ជីគ្រួសារ
- លិខិតបញ្ជាក់មរណភាពដែលចេញដោយមូលដ្ឋានសុខាភិបាល ឬស្ថាប័នមានសមត្ថកិច្ច
- សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ។

**ប្រការ១១.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គមអាចសម្រេចផ្តល់ការឧបត្ថម្ភស្បៀងអាហារ ក្នុងទម្រង់ជាសាច់ប្រាក់ក្រោមរបបគោល ដល់រដ្ឋបាលរាជធានី ខេត្ត តាមការចាំបាច់ តាមសំណើរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។

ក្នុងករណីចាំបាច់ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គមអាចពិគ្រោះយោបល់ជាមួយប្រធានក្រុមការងារចំពោះកិច្ចគ្រប់គ្រងការផ្គត់ផ្គង់ និងថ្លៃទំនិញយុទ្ធសាស្ត្រ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ក្នុងការលើកសំណើពាក់ព័ន្ធនឹងការឧបត្ថម្ភស្បៀងអាហារ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គមពិនិត្យ សម្រេច។

**ប្រការ១២.-**

រដ្ឋបាលរាជធានី ខេត្ត ត្រូវចាត់ចែងមធ្យោបាយដឹកជញ្ជូនកញ្ចប់ឧបត្ថមស្បៀងអាហារដែលទទួលបានការសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម ដោយចាត់ឱ្យមានតំណាងទទួលដែលមានលិខិតឧទ្ទេសនាមភ្ជាប់មកជាមួយ ទៅតាមការសម្របសម្រួល និងទីតាំងដូចមានក្នុងឧបសម្ព័ន្ធទី ៣ នៃសេចក្តីសម្រេចនេះ។

**ប្រការ១៣.-**

រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំសំណើសុំទូទាត់ជម្រះ ក្នុងរយៈពេលពី ៤ ទៅ ៦ សប្តាហ៍បន្ទាប់ពីថ្ងៃបើកថវិកាបុរេប្រទាន និងកញ្ចប់ឧបត្ថម្ភស្បៀងអាហារ ដោយត្រូវភ្ជាប់ជាមួយឯកសារពាក់ព័ន្ធ តាមគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី២ នៃសេចក្តីសម្រេចនេះ ដើម្បីដាក់ជូនអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម សម្របសម្រួលនីតិវិធីក្នុងការពិនិត្យ និងសម្រេចទូទាត់។ ការទូទាត់ត្រូវធ្វើឡើងដោយអាណត្តិបើកប្រាក់របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងត្រូវឆ្លងការត្រួតពិនិត្យ និងផ្តល់ទិដ្ឋាការពីអភិបាលហិរញ្ញវត្ថុ។

## ជំពូកទី៥
## ការតាមដាន និងប្រតិភូលក្ខារលើការអនុវត្តកម្មវិធី

**ប្រការ១៤.-**

ក្រុមប្រឹក្សាជាតិគាំពារសង្គម ដែលមានអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គមជាសេនាធិការ ត្រូវទទួលភារកិច្ចក្នុងការតាមដាន និងធ្វើប្រតិភូលក្ខការលើការអនុវត្តវិធានការអន្តរាគមន៍ជំនួយសង្គមរបស់រាជរដ្ឋាភិបាល ដើម្បីគាំពារប្រជាពលរដ្ឋដែលរងគ្រោះ ឬរងផលប៉ះពាល់ធ្ងន់ធ្ងរ ពីជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ ទាំងក្នុងអំឡុងពេលអនុវត្ត និងក្រោយកាលបរិច្ឆេទនៃការអនុវត្តកម្មវិធី។

## ជំពូកទី៦
## រយៈពេលនៃការអនុវត្ត

**ប្រការ១៥.-**

វិធានការអន្តរាគមន៍ជំនួយសង្គមរបស់រាជរដ្ឋាភិបាល ដើម្បីគាំពារប្រជាពលរដ្ឋដែលរងគ្រោះ ឬរងផលប៉ះពាល់ធ្ងន់ធ្ងរ ពីជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ ត្រូវដាក់ឱ្យអនុវត្តចាប់ពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០២១ តទៅ រហូតដល់មានការកំណត់ជាថ្មី តាមរយៈសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**ប្រការ១៦.-**

អនុប្រធាន និងសមាជិកក្រុមប្រឹក្សាជាតិគាំពារសង្គម, រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី, ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការប្រតិបត្តិ នៃក្រុមប្រឹក្សាជាតិគាំពារសង្គម, នាយកខុទ្ទកាល័យ, អគ្គលេខាធិការ, ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក, អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន, អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសៅរ៍ ៦ កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ១៦ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធទី១ នៃសេចក្តីសម្រេចលេខ ....០១៨..........សហវ ចុះថ្ងៃទី២៧..ខែមេសា..ឆ្នាំ២០២១ ស្តីពីយន្តការ និងនីតិវិធីនៃការអនុវត្តវិធានការគោលនយោបាយអន្តរាគមន៍ជំនួយសង្គមរបស់រាជរដ្ឋាភិបាល ដើម្បីគាំពារប្រជាពលរដ្ឋដែលរងគ្រោះ ឬរងផលប៉ះពាល់ធ្ងន់ធ្ងរ ពីជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១**

គំរូលិខិតបុរេប្រទាន

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលរាជធានី/ខេត្ត......**

**សូមគោរពជូន**

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កម្មវត្ថុ÷** សំណើសុំថវិកាបុរេប្រទានចំនួន.................... **រៀល** និងកញ្ចប់ឧបត្ថម្ភស្បៀងអាហារសម្រាប់បើកផ្តល់ សម្រាប់អនុវត្តវិធានការគោលនយោបាយអន្តរាគមន៍ជំនួយសង្គមរបស់រាជរដ្ឋាភិបាល ដើម្បីគាំពារប្រជាពលរដ្ឋដែលរងគ្រោះ ឬរងផលប៉ះពាល់ធ្ងន់ធ្ងរ ពីជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ ក្នុងខែ..... ។

**យោង÷** សេចក្តីសម្រេចលេខ ..................ចុះថ្ងៃទី...... ខែមេសា ឆ្នាំ២០២១ ស្តីពីយន្តការ និងនីតិវិធីនៃការអនុវត្តវិធានការគោលនយោបាយអន្តរាគមន៍ជំនួយសង្គមរបស់រាជរដ្ឋាភិបាល ដើម្បីគាំពារប្រជាពលរដ្ឋដែលរងគ្រោះ ឬរងផលប៉ះពាល់ធ្ងន់ធ្ងរ ពីជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១

សេចក្តីដូចមានក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា÷ ផ្អែកលើតួលេខ និងការប៉ាន់ស្មាន ក្នុងខែ..... រដ្ឋបាលរាជធានី-ខេត្ត...... នឹងត្រូវការបើកផ្តល់កញ្ចប់ថវិកាជំនួយសង្គមពិសេស និងកញ្ចប់ឧបត្ថម្ភស្បៀងអាហារ ជូនគ្រួសារដែលរងគ្រោះ ឬរងផលប៉ះពាល់ធ្ងន់ធ្ងរ ពីជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ ដែលមានសរុបប្រមាណចំនួន ........គ្រួសារ។ ដើម្បីឱ្យយន្តការនៃការអនុវត្តវិធានការនេះមានភាពរលូន និងទទួលបានជោគជ័យ រដ្ឋបាលរាជធានី-ខេត្ត...... សូមគោរពស្នើសុំថវិកាបុរេប្រទានចំនួន .................. (**លេខជាអក្សរ** )**រៀល** និងស្បៀងដូចជា អង្ករចំនួន........តោន, មីចំនួន........ កេសតូច, ទឹកត្រីចំនួន........ យួរ និងទឹកស៊ីអ៊ីវចំនួន........ យួរ ដូចមានក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ជូន។

ចំពោះថវិកាបុរេប្រទានសូមបង្វែរចូលគណនីនៅធនាគារ.................... ដែលមានព័ត៌មានលម្អិតដូចខាងក្រោម÷

| **ព័ត៌មានលម្អិតអំពីគណនី** | |
|---|---|
| ឈ្មោះធនាគារ | |
| ឈ្មោះគណនី | |
| លេខគណនី | |
| អាសយដ្ឋានរបស់ម្ចាស់គណនី | |
| អាសយដ្ឋានរបស់ធនាគារ | |

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤

............ ថ្ងៃទី ខែ ឆ្នាំ២០២១

**អភិបាលរាជធានី-ខេត្ត ......**

# គំរូតារាងគម្រោងចំណាយថវិកា និងកញ្ចប់ឧបត្ថម្ភស្បៀងអាហារយោងតាមបញ្ជីគ្រួសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានី-ខេត្ត ......

ឃុំ/សង្កាត់...............

## តារាងគម្រោងចំណាយថវិកា និងកញ្ចប់ឧបត្ថម្ភស្បៀងអាហារយោងតាមបញ្ជីគ្រួសារ

គ្រួសារដែលទទួលរងការធ្វើចត្តាឡីស័កនៅក្នុងតំបន់បិទខ្ទប់

| ចំនួនសមាជិកគ្រួសារ | ចំនួនគ្រួសារ | ប្រាក់ឧបត្ថម្ភ | ប្រាក់ឧបត្ថម្ភលើថ្លៃទឹក ចំនួន២ខែ | ប្រាក់ឧបត្ថម្ភលើថ្លៃភ្លើង ចំនួន២ខែ | អង្ករ ១បាវ (២៥ គីឡូក្រាម) | ត្រី ១ កេសតូច | ទឹកត្រី ១ យួរ | ទឹកស៊ីអ៊ីវ ១ យួរ |
|---|---|---|---|---|---|---|---|---|
| ១ នាក់ | | | | | | | | |
| ២ - ៣ នាក់ | | | | | | | | |
| ចាប់ពី ៤ នាក់ ឡើងទៅ | | | | | | | | |
| សរុប | | | | | | | | |

គ្រួសារដែលមានសមាជិកឆ្លងជំងឺកូវីដ-១៩

| ចំនួនសមាជិកគ្រួសារ | ចំនួនគ្រួសារ | ថវិកា | ប្រាក់ឧបត្ថម្ភលើថ្លៃទឹក ចំនួន៣ខែ | ប្រាក់ឧបត្ថម្ភលើថ្លៃភ្លើង ចំនួន៣ខែ | អង្ករ ១បាវ (២៥ គីឡូក្រាម) | ត្រី ១ កេសតូច | ទឹកត្រី ១ យួរ | ទឹកស៊ីអ៊ីវ ១ យួរ |
|---|---|---|---|---|---|---|---|---|
| ១ នាក់ | | | | | | | | |
| ២ - ៣ នាក់ | | | | | | | | |
| ចាប់ពី ៤ នាក់ ឡើងទៅ | | | | | | | | |
| សរុប | | | | | | | | |

គ្រួសារដែលមានសមាជិកស្លាប់ដោយសារជំងឺកូវីដ-១៩

| ចំនួនសមាជិកគ្រួសារ | ចំនួនគ្រួសារ | ថវិកា | ប្រាក់ឧបត្ថម្ភលើថ្លៃទឹក ចំនួន៥ខែ | ប្រាក់ឧបត្ថម្ភលើថ្លៃភ្លើង ចំនួន៥ខែ | អង្ករ ១បាវ (២៥ គីឡូក្រាម) | ត្រី ១ កេសតូច | ទឹកត្រី ១ យួរ | ទឹកស៊ីអ៊ីវ ១ យួរ |
|---|---|---|---|---|---|---|---|---|
| ១ នាក់ | | | | | | | | |
| ២ - ៣ នាក់ | | | | | | | | |
| ចាប់ពី ៤ នាក់ ឡើងទៅ | | | | | | | | |
| សរុប | | | | | | | | |

.........ថ្ងៃទី ខែ ឆ្នាំ២០២១

អ្នករៀបចំ

បានពិនិត្យ និងផ្ទៀងផ្ទាត់

..............ថ្ងៃទី ខែ ឆ្នាំ២០២១

ប្រធាន.........

បានឃើញ និងឯកភាព

.........ថ្ងៃទី ខែ ឆ្នាំ២០២១

អភិបាលរាជធានី-ខេត្ត ......

**ឧបសម្ព័ន្ធទី២ នៃសេចក្តីសម្រេចលេខ ...០១៨............សហវ ចុះថ្ងៃទី១៧...ខែមេសា ឆ្នាំ២០២១ ស្តីពី យន្តការ និងនីតិវិធីនៃការអនុវត្តវិធានការគោលនយោបាយអន្តរាគមន៍ជំនួយសង្គមរបស់រាជរដ្ឋាភិបាល ដើម្បីគាំពារប្រជាពលរដ្ឋដែលរងគ្រោះ ឬរងផលប៉ះពាល់ធ្ងន់ធ្ងរ ពីជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១**

គំរូលិខិតស្នើសុំទូទាត់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានី-ខេត្ត ......**

**សូមគោរពជូន**

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កម្មវត្ថុ៖** សំណើសុំទូទាត់ និងបំពេញឡើងវិញនូវថវិកាចំនួន .................... **រៀល** និងកញ្ចប់ឧបត្ថម្ភស្បៀងអាហារ សម្រាប់បើកផ្តល់ សម្រាប់អនុវត្តវិធានការគោលនយោបាយអន្តរាគមន៍ជំនួយសង្គមរបស់រាជរដ្ឋាភិបាល ដើម្បីគាំពារប្រជាពលរដ្ឋដែលរងគ្រោះ ឬរងផលប៉ះពាល់ធ្ងន់ធ្ងរ ពីជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ ក្នុងខែ...។

**យោង៖** លិខិតលេខ ............... ចុះថ្ងៃទី........ខែ...............ឆ្នាំ................របស់រដ្ឋបាលរាជធានី-ខេត្ត.........។

សេចក្តីដូចមានក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា៖ រដ្ឋបាលរាជធានី-ខេត្ត....... បានទទួលថវិកាបុរេប្រទាន និងកញ្ចប់ឧបត្ថម្ភស្បៀងអាហារ សម្រាប់ប្រតិបត្តិការបើកផ្តល់ជូនប្រជាពលរដ្ឋដែលរងគ្រោះ ឬរងផលប៉ះពាល់ធ្ងន់ធ្ងរ ពីជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ ក្នុងខែ..... ខាងក្រោមនេះជាតម្រោងលម្អិត និងត្រូវស្នើសុំជាថ្មី៖

| មុខចំណាយ | បុរេប្រទានក្នុងខែ...... | ចំណាយជាក់ស្តែង | ស្នើសុំថ្មី |
|---|---|---|---|
| ថវិកា | | | |
| អង្ករ | | | |
| មី | | | |
| ទឹកត្រី | | | |
| ទឹកស៊ីអ៊ីវ | | | |

ដើម្បីឱ្យយន្តការនៃការអនុវត្តវិធានការនេះមានភាពរលូន និងទទួលបានជោគជ័យ រដ្ឋបាលរាជធានី-ខេត្ត ............ សូមគោរពស្នើសុំថវិកាបំពេញឡើងវិញនូវថវិកាចំនួន ................................ (**លេខជាអក្សរ**)**រៀល** និងស្បៀងដូចជា អង្ករចំនួន........តោន, មីចំនួន ........ កេសតូច, ទឹកត្រីចំនួន ........ យួរ និងទឹកស៊ីអ៊ីវចំនួន ........ យួរ សម្រាប់ធ្វើប្រតិបត្តិការបើកផ្តល់ជូនគ្រួសារគោលដៅបន្ទាប់ទៀត។ ចំពោះថវិកាបុរេប្រទានសូមបង្វែរចូលគណនីនៅធនាគារ .................... ដែលមានព័ត៌មានលម្អិតដូចខាងក្រោម៖

| **ព័ត៌មានលម្អិតអំពីគណនី** | |
|---|---|
| ឈ្មោះធនាគារ | |
| ឈ្មោះគណនី | |
| លេខគណនី | |
| អាសយដ្ឋានរបស់ម្ចាស់គណនី | |
| អាសយដ្ឋានរបស់ធនាគារ | |

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤

........... ថ្ងៃទី ខែ ឆ្នាំ២០២១

**អភិបាលសាលារាជធានី-ខេត្ត.........**

## គំរូបណ្ណចំណាយ

**រដ្ឋបាលរាជធានី-ខេត្ត ......**

**នាយកដ្ឋានហិរញ្ញវត្ថុ**

**កញ្ចប់ជំនួយសង្គមពិសេស**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# បណ្ណចំណាយ

កាលបរិច្ឆេទ÷.................. លេខរៀង÷

| | |
|---|---|
| - បើកជូន: | លោក/ លោកស្រី .................... |
| - អាសយដ្ឋាន: | ............................. |
| - កម្មវត្ថុ: | .............................. |
| - ចំនួន: | XXXXXX |
| - ចំនួន (ជាអក្សរ) | ........................ |
| - មូលប្បទានបត្រ/ សាច់ប្រាក់ | XXXXXX |
| -លេខគណនី | XXXXXX |
| -គម្រោង: | កញ្ចប់ជំនួយសង្គមពិសេស |

| អ្នករៀបចំ | បានពិនិត្យ និងផ្ទៀងផ្ទាត់ | បានឃើញ និងឯកភាព |
|---|---|---|
| មន្ត្រីផ្នែកហិរញ្ញវត្ថុ | ប្រធានផ្នែកហិរញ្ញវត្ថុ | អភិបាលរាជធានី-ខេត្ត... |

គំរូតារាងសង្ខេបមុខចំណាយ

រដ្ឋបាលរាជធានី-ខេត្ត ......
នាយកដ្ឋានហិរញ្ញវត្ថុ
កញ្ចប់ថវិកាសង្គមកិច្ចពិសេស

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**តារាងសង្ខេបមុខចំណាយ**

**រយៈពេល÷ ..................................................**

| ល.រ. | ចំណាយតាមមុខសញ្ញា | ទឹកប្រាក់សរុប |
|---|---|---|
| 1 | ខ្ទង់ទី១: កញ្ចប់សាច់ប្រាក់បើកផ្តល់ជូនគ្រួសារគោលដៅ | |
| 2 | ខ្ទង់ទី២: កញ្ចប់ឧបត្ថម្ភស្បៀងអាហារដែលបើកផ្តល់ជូនគ្រួសារគោលដៅ | |
| 3 | ខ្ទង់ទី៣: ចំណាយផ្សេងៗ | |
| | Total | - |

| អ្នករៀបចំ | បានពិនិត្យ និងផ្ទៀងផ្ទាត់ | បានឃើញ និងឯកភាព |
|---|---|---|
| មន្ត្រីផ្នែកហិរញ្ញវត្ថុ | ប្រធានផ្នែកហិរញ្ញវត្ថុ | អភិបាលរាជធានី- ខេត្ត ...... |
| កាលបរិច្ឆេទ:....................... | កាលបរិច្ឆេទ:....................... | កាលបរិច្ឆេទ:....................... |

# គំរូតារាងចំណាយលម្អិតមុខចំណាយ

រដ្ឋបាលរាជធានី-ខេត្ត ......
នាយកដ្ឋានហិរញ្ញវត្ថុ
គណនីជំនួយសង្គមពិសេស

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**តារាងចំណាយលម្អិតមុខចំណាយ**

**រយៈពេល÷ ........................................**

☑ បំពេញបន្ថែម ☐ ទូទាត់ដោយផ្ទាល់

| ល.រ. | បរិយាយ | បណ្ណចំណាយ | | | |
|---|---|---|---|---|---|
| | | លេខរៀង | កាលបរិច្ឆេទ | ចំនួនទឹកប្រាក់ | សាច់ប្រាក់/មូលប្បទានបត្រ |
| ខ្ទង់ទី១: គណនីសាច់ប្រាក់បើកផ្តល់ជូនគ្រួសារគោលដៅ | | | | | |
| 1 | | | | | |
| 2 | | | | | |
| | **សរុបខ្ទង់ទី១** | | | - | |
| ខ្ទង់ទី២: គណនីឧបត្ថម្ភស្បៀងអាហារដែលបើកផ្តល់ជូនគ្រួសារគោលដៅ | | | | | |
| 1 | | | | | |
| 2 | | | | | |
| | **សរុបខ្ទង់ទី២** | | | - | |
| ខ្ទង់ទី៣: ចំណាយផ្សេងៗ | | | | | |
| 1 | | | | | |
| 2 | | | | | |
| | **សរុបខ្ទង់ទី៣** | | | - | |
| | | | | | |

-

អ្នករៀបចំ

មន្ត្រីផ្នែកហិរញ្ញវត្ថុ

កាលបរិច្ឆេទ:........................

បានពិនិត្យ និងផ្ទៀងផ្ទាត់

ប្រធានផ្នែកហិរញ្ញវត្ថុ

កាលបរិច្ឆេទ:........................

បានឃើញ និងឯកភាព

អភិបាលរាជធានី-ខេត្ត ......

កាលបរិច្ឆេទ:........................

គំរូតារាងចំណាយ

រដ្ឋបាលរាជធានី-ខេត្ត ......
នាយកដ្ឋានហិរញ្ញវត្ថុ
កញ្ចប់ជំនួយសង្គមពិសេស

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងចំណាយ

ឈ្មោះធនាគារ | លេខគណនី
អាសយដ្ឋានធនាគារ | រយៈពេល÷ .................................

| កាលបរិច្ឆេទ | លេខរៀងបណ្ណចំណាយ | បរិយាយ | មូលប្បទានបត្រ/ សាច់ប្រាក់ | អ្នកទទួល | ឥណពន្ធ | ឥណទាន | សមតុល្យ |
|---|---|---|---|---|---|---|---|
| | | សាច់ប្រាក់ដើមគ្រា | | | 10,000.00 | | 10,000.00<br>10,000.00<br>10,000.00<br>10,000.00<br>10,000.00<br>10,000.00<br>10,000.00<br>10,000.00<br>10,000.00<br>10,000.00 |
| | | សរុប | | | 10,000.00 | - | 10,000.00 |

................ថ្ងៃទី ខែ ឆ្នាំ២០២១
**អ្នករៀបចំ**

បានពិនិត្យ និងផ្ទៀងផ្ទាត់
................ថ្ងៃទី ខែ ឆ្នាំ២០២១
**ប្រធានហិរញ្ញវត្ថុ**

បានឃើញ និងឯកភាព
................ថ្ងៃទី ខែ ឆ្នាំ២០២១
**អភិបាលរាជធានី-ខេត្ត ......**

គំរូបញ្ជីគ្រួសារដែលទទួលរងការធ្វើចត្តាឡីស័ក នៅក្នុងតំបន់ដែលត្រូវបានអនុវត្តវិធានការបិទខ្ទប់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានី-ខេត្ត ......**
**ឃុំ/សង្កាត់................**

**បញ្ជីគ្រួសារដែលទទួលរងការធ្វើចត្តាឡីស័ក នៅក្នុងតំបន់ដែលត្រូវបានអនុវត្តវិធានការបិទខ្ទប់**

| ល.រ | ឈ្មោះមេគ្រួសារ | ចំនួនសមាជិក | លេខអត្តសញ្ញាណប័ណ្ណ | លេខទូរស័ព្ទ | ថវិកាដែលឧបត្ថម្ភក្នុង១គ្រួសារ | ថវិកាឧបត្ថម្ភសម្រាប់ថ្លៃទឹក ចំនួន២ខែ | ថវិកាឧបត្ថម្ភសម្រាប់ថ្លៃភ្លើង ចំនួន២ខែ | អង្ករ | មី | ទឹកត្រី | ទឹកស៊ីអ៊ីវ | ហត្ថលេខាអ្នកទទួល |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | | | | | | | | | | | | |
| ២ | | | | | | | | | | | | |
| ៣ | | | | | | | | | | | | |
| ៤ | | | | | | | | | | | | |
| ៥ | | | | | | | | | | | | |
| ៦ | | | | | | | | | | | | |
| | សរុប | | | | | | | | | | | |

................ថ្ងៃទី ខែ ឆ្នាំ២០២១
**អ្នករៀបចំ**

បានពិនិត្យ និងផ្ទៀងផ្ទាត់
................ថ្ងៃទី ខែ ឆ្នាំ២០២១
**ប្រធាន..........**

បានឃើញ និងឯកភាព
..................ថ្ងៃទី ខែ ឆ្នាំ២០២១
**អភិបាលរាជធានី-ខេត្ត ......**

# គំរូបញ្ជីគ្រួសារដែលមានសមាជិកឆ្លងជំងឺកូវីដ-១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានី-ខេត្ត ......
ឃុំ/សង្កាត់................

## បញ្ជីគ្រួសារដែលមានសមាជិកឆ្លងជំងឺកូវីដ-១៩

| ល.រ | ឈ្មោះមេគ្រួសារ | លេខអត្តសញ្ញាណប័ណ្ណ | លេខទូរស័ព្ទ | ចំនួនសមាជិក | ចំនួនអ្នកឆ្លងជំងឺកូវីដ-១៩ | ឈ្មោះអ្នកឆ្លងជំងឺកូវីដ-១៩ | ថ្ងៃដែលរកឃើញវិជ្ជមាន | ថវិកាដែលឧបត្ថម្ភដល់គ្រួសារ | ថវិកាឧបត្ថម្ភសម្រាប់ថ្លៃទឹក ចំនួន៣ខែ | ថវិកាឧបត្ថម្ភសម្រាប់ថ្លៃភ្លើង ចំនួន៣ខែ | អង្ករ | ត្រី | ទឹកត្រី | ទឹកស៊ីអ៊ីវ | ហត្ថលេខាអ្នកទទួល |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | | | | | | | | | | | | | | | |
| ២ | | | | | | | | | | | | | | | |
| ៣ | | | | | | | | | | | | | | | |
| ៤ | | | | | | | | | | | | | | | |
| ៥ | | | | | | | | | | | | | | | |
| ៦ | | | | | | | | | | | | | | | |
| | សរុប | | | | | | | | | | | | | | |

..........ថ្ងៃទី ខែ ឆ្នាំ២០២១
**អ្នករៀបចំ**

បានពិនិត្យ និងផ្ទៀងផ្ទាត់
..........ថ្ងៃទី ខែ ឆ្នាំ២០២១
**មេឃុំ**.........

បានឃើញ និងឯកភាព
..........ថ្ងៃទី ខែ ឆ្នាំ២០២១
**អភិបាលរាជធានី-ខេត្ត** ......

# គំរូបញ្ជីគ្រួសារដែលមានសមាជិកស្លាប់ដោយសារជំងឺកូវីដ-១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានី-ខេត្ត ......
ឃុំ/សង្កាត់...............

## បញ្ជីគ្រួសារដែលមានសមាជិកស្លាប់ដោយសារជំងឺកូវីដ-១៩

| ល.រ | ឈ្មោះមេគ្រួសារ | លេខអត្តសញ្ញាណប័ណ្ណ | លេខទូរស័ព្ទ | ចំនួនសមាជិក | ចំនួនស្លាប់ដោយសារជំងឺកូវីដ-១៩ | ឈ្មោះអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ | ថ្ងៃដែលគេឃើញថាមានជំងឺ | ថវិកាដែលត្រូវផ្តល់ជូនគ្រួសារ | ថវិកាឧបត្ថម្ភសម្រាប់ថ្ងៃទី... ចំនួនដង | ថវិកាឧបត្ថម្ភសម្រាប់ថ្ងៃ... ចំនួនដង | ភូមិ | ឃុំ | ទីក្រុង | ទីតាំងភូមិ | ហត្ថលេខាអ្នកទទួល |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | | | | | | | | | | | | | | | |
| ២ | | | | | | | | | | | | | | | |
| ៣ | | | | | | | | | | | | | | | |
| ៤ | | | | | | | | | | | | | | | |
| ៥ | | | | | | | | | | | | | | | |
| ៦ | | | | | | | | | | | | | | | |
| | សរុប | | | | | | | | | | | | | | |

............ថ្ងៃទី ខែ ឆ្នាំ២០២១
**អ្នករៀបចំ**

បានពិនិត្យ និងផ្ទៀងផ្ទាត់
............ថ្ងៃទី ខែ ឆ្នាំ២០២១
**ប្រធាន..........**

បានឃើញ និងឯកភាព
............ថ្ងៃទី ខែ ឆ្នាំ២០២១
**អភិបាលរាជធានី-ខេត្ត ......**

## ឧបសម្ព័ន្ធទី៣
## បញ្ជីរាយនាមអ្នកសម្របសម្រួលរបស់ក្រុមហ៊ុនហ្គ្រីនត្រេដ
## និងទីតាំងដែលបានកំណត់សម្រាប់ការមកទទួលស្បៀងអាហាររបស់គំណាងរដ្ឋបាលរាជធានី ខេត្ត

### ក. អ្នកសម្របសម្រួលរបស់ក្រុមហ៊ុន ហ្គ្រីនត្រេដ

| អ្នកសម្របសម្រួល | តួនាទី | សម្ភារៈ | លេខទូរស័ព្ទ |
|---|---|---|---|
| ឯកឧត្តម ចាន់ សុខទី | ទទួលបន្ទុកគ្រប់គ្រងរួម | | ០១២ ២២២ ៧៩៧ |
| លោក ជន វីរៈ | ប្រធាននាយកដ្ឋានមណ្ឌលឃ្លាំង | សម្រាប់អង្ករ | ០១២ ៩២០ ៩១៥ |
| លោកពេជ្រ សំអាត | ប្រធាននាយកដ្ឋានបច្ចេកទេស | សម្រាប់មី | ០១២ ៩៤៣ ០៧២ |
| លោកស្រី អាន ផានី | ប្រធាននាយកដ្ឋានអាជីវកម្ម | សម្រាប់ទឹកត្រី ទឹកស៊ីអ៊ីវ | ០១២ ២៥២ ៩២៧ |

### ខ. ទីតាំងដែលបានកំណត់សម្រាប់ការមកទទួលស្បៀងអាហារ

| **១. ឃ្លាំងស្តុកអង្ករ ត.ម.លេខ៦** | |
|---|---|
| អាសយដ្ឋាន ÷ | ផ្លូវជាតិលេខ ៥ ភូមិស្ពានខ្ពស់ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ |
| លេខទូរស័ព្ទ ÷ | ០១២ ២២២ ៧៩៧, ០១២ ៩២០ ៩១៥ |
| **២. ឃ្លាំងស្តុកមីជាតិ** | |
| អាសយដ្ឋាន ÷ | ភូមិភ្លូផ្អែម ផ្លូវមហាវិថីឈ្នះឈ្នះ សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ |
| លេខទូរស័ព្ទ ÷ | ០១២ ៩៤៣ ០៧២, ០១២ ២៥២ ៩៥៧, ០៩៥ ៦៥៥ ៣៤៣ |
| **៣. ឃ្លាំងស្តុកមីយើង (រោងចក្រផលិតម្សៅមី ម៉ែន សារុន)** | |
| អាសយដ្ឋាន ÷ | ផ្លូវជាតិលេខ៥ ភូមិខ្វង សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ |
| លេខទូរស័ព្ទ ÷ | ០១៧ ២៥២ ៩២៧, ០១២ ៩៣០ ៣១៣ |
| **៤. ឃ្លាំងទឹកត្រី ទឹកស៊ីអ៊ីវ** | |
| អាសយដ្ឋាន ÷ | #254 GA, ផ្លូវទន្លេមេគង្គ ភូមិ ៣ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ |
| លេខទូរស័ព្ទ ÷ | ០១៧ ២៥២ ៩២៧, ០១២ ៨៨០ ៣៣៦, ០១២ ៩៤៣ ០៧២ |